**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល មាត្រា១ មាត្រា៥ មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យ លេខ ១២៥ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យ លេខ ១២៥ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ស្តីពីនិរាករណ៍អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងអនុក្រឹត្យលេខ ១៤ អនក្រ.បក

www.pheakdeylaw.com

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកែសម្រួលអនុក្រឹត្យ លេខ ៣៩ អនក្រ.បក ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**មាត្រា មួយ. -**

ត្រូវបានកែសម្រួលមាត្រា១ មាត្រា៥ មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ១. -ថ្មី**

នាយកដ្ឋាននគរបាលទេសចរណ៍ ស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ៥. -ថ្មី** (មាត្រា៦ ចាស់)

នាយកដ្ឋាននគរបាលទេសចរណ៍ មានសមត្ថកិច្ច និងភារកិច្ច ដូចខាងក្រោម ÷

១- អនុវត្តគោលនយោបាយជាតិលើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- លើកគោលការណ៍ ផែនការ និងវិធានការ ដឹកនាំបញ្ជាជំនាញនគរបាលទេសចរណ៍ អនុវត្តភារកិច្ចថែរក្សាការពារសន្តិសុខ សុវត្ថិភាពជូនទេសចរជាតិ និងអន្តរជាតិ ។

៣- ក្នុងនាមក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋាននគរបាលទេសចរណ៍ មានសិទ្ធិធ្វើទំនាក់ទំនងជាមួយស្ថានទូត ស្ថានតំណាង និងអង្គការអន្តរជាតិនានា ដើម្បីផ្តល់ និងទទួលព័ត៌មាន ជុំវិញហេតុការណ៍ ដែលពាក់ព័ន្ធដល់ទេសចរ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចំណាត់ការឱ្យបានសមស្រប និងទាន់ពេលវេលា តាមការកំណត់ នៃច្បាប់ជាធរមាន ។

៤- ករណីមានបទល្មើសជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន មន្ត្រីនគរបាលទេសចរណ៍ត្រូវធ្វើអន្តរាគមន៍ចំពោះបទល្មើសនោះ ទៅតាមនីតិវិធីជាធរមាន ។

៥- សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការប្រព្រឹត្តបទល្មើស ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ សម្បត្តិធម្មជាតិ និងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ព្រមទាំងអនុវត្តវិធានការមុខជំនាញ តាមគោលការណ៍ដឹកនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

៦- អនុវត្តមុខងារជានគរបាលយុត្តិធម៌ ទទួល និងធ្វើកំណត់ហេតុរាល់បណ្តឹងអំពីការបាត់ខ្លួន រាល់សកម្មភាព ឬអំពើរំលោភបំពារបំពានទាំងឡាយណា ដែលប៉ះពាល់រូបរាងកាយ សុខភាព អាយុជីវិត ផលប្រយោជន៍ ទ្រព្យសម្បត្តិ និងកិត្តិយសរបស់ទេសចរ ។ ឃាត់ខ្លួន ចាប់ខ្លួនជនល្មើសនិងដកហូតវត្ថុតាង កសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

៧- អនុវត្តសាលក្រម សាលដីកា សេចក្តីសម្រេចរបស់តុលាការ និងអយ្យការគ្រប់ថ្នាក់ ។

www.pheakdeylaw.com

៨- សហការជាមួយអង្គភាពពាក់ព័ន្ធនានា ដើម្បីមានវិធានការការពារ និងដោះស្រាយឧប្បត្តិហេតុគ្រោះថ្នាក់ផ្សេងៗ ដែលកើតឡើង ឬ អាចកើតឡើងជាយថាហេតុ ដោយភាពស្មោះត្រង់ និងថែរក្សាទ្រព្យសម្បត្តិ សន្តិសុខ សុវត្ថិភាព ជូនដល់ទេសចរ ប្រកបដោយវិជ្ជាជីវៈ ។

៩- សហការជាមួយអង្គភាពពាក់ព័ន្ធនានា ផ្តើមស្មើនូវវិធានការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់ដឹង និងចូលរួមអនុវត្តគោលនយោបាយជាតិលើវិស័យទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១០-សហការជាមួយមន្ទីរទេសចរណ៍រាជធានី-ខេត្ត អង្គភាព សមត្ថកិច្ចពាក់ព័ន្ធនានា និងរដ្ឋបាលក្រោមជាតិគ្រប់លំដាប់ថ្នាក់ ដើម្បីទទួលព័ត៌មានពីទេសចរ ដែលចូលមកធ្វើទស្សនកិច្ចទេសចរណ៍ក្នុងភូមិសាស្ត្ររបស់ខ្លួន ។

១១-ចាត់តាំង ដឹកនាំយន្តការ និងរៀបចំបណ្តាញអ្នកស្ម័គ្រចិត្តរបស់សហគមជាតិ អន្តរជាតិ ដើម្បីជាជំនួយដល់កិច្ចការសន្តិសុខ សុវត្ថិភាព ជូនទេសចរនៅតាមតំបន់ទេសចរណ៍នីមួយៗ ដោយសហការជាមួយសមត្ថកិច្ច នៃក្រសួងទេសចរណ៍ ។

១២-ផ្តល់ព័ត៌មានពិត ច្បាស់លាស់ និងមិនលំអៀង ជូនទេសចរពីគោលដៅទស្សនកិច្ច ស្ថានភាពសន្តិសុខ សណ្តាប់ធ្នាប់ ដើម្បីផាសុកភាព សុវត្ថិភាព ។

១៣-បោះទីតាំងប្រចាំការការពារ និងល្បាតចល័តតាមចំណុច ដែលមានការប្រមូលផ្តុំទេសចរដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការផ្តល់ ទទួលព័ត៌មាន និងអន្តរាគមន៍ទាន់ពេលវេលា សំដៅធានាសុវត្ថិភាពដល់ទេសចរ ។

១៤-ជួយសម្របសម្រួលការធ្វើដំណើរ ការដឹកជញ្ជូនទេសចរ កិច្ចការលិខិតស្នាម និងបែបបទរដ្ឋបាល ព្រមទាំងផ្តល់ភាពកក់ក្តៅ ជឿទុកចិត្តក្នុងភាពស្មោះត្រង់ និងរួសរាយរាក់ទាក់ ដោយមិនប្រកាន់សញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ ឋានៈ និងសាសនា ជូនទេសចរអំឡុងពេលទស្សនកិច្ចស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១៥-ធ្វើរបាយការណ៍ជាប្រចាំតាមការកំណត់ ឬ ក្នុងករណីមានហេតុការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធទៅនឹងការអនុវត្តមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួន ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

១៦-ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យ របស់អង្គភាពខ្លួនតាមការកំណត់របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ និងទទួលប្រាក់ឧបត្ថម្ភពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានសម្រេចផ្តល់ឱ្យក្នុងទេសចរម្នាក់ ដោយបញ្ចូលក្នុងឧបសម្ព័ន្ធ នៃថវិការបស់ក្រសួងមហាផ្ទៃ ដើម្បីទិញឧបករណ៍សម្ភារៈបំពាក់ជូនកងកម្លាំងនគរបាលទេសចរណ៍ សម្រាប់ប្រើប្រាស់ក្នុងទិសដៅ ថែរក្សាការពារសន្តិសុខ សុវត្ថិភាព និងអន្តរាគមន៍ជូនជនទេសចរ ប្រកបដោយប្រសិទ្ធភាព ។

១៧-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤ ថ្មី

## អំពីភារកិច្ចក្រសួងពាក់ព័ន្ធ

**មាត្រា ៧.-ថ្មី**

១-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អាចចូលរួមផ្តល់យោបល់លើការតែងតាំងមុខតំណែង និង/ឬតម្លើងឋានន្តរសក្តិ

www.pheakdeylaw.com

និង/ឬដាក់ពិន័យ មន្ត្រីនគរបាលទេសចរណ៍។

២-ក្រសួងទេសចរណ៍ត្រូវផ្តល់ឯកសារ សៀវភៅ ទស្សនាវដ្តី ព្រឹត្តិប័ត្រ ប័ណ្ណផ្ទត់ ដល់មន្ត្រីនគរបាលទេសចរណ៍ ដើម្បីសិក្សាស្រាវជ្រាវលើកកម្ពស់ការយល់ដឹងអំពីវិស័យទេសចរណ៍។

៣-ក្រសួងទេសចរណ៍អាចស្នើសុំមន្ត្រីនគរបាលទេសចរណ៍ពីក្រសួងមហាផ្ទៃ ដើម្បីការពារសន្តិសុខ សុវត្ថិភាព ជូនទេសចរ។

៤-ក្រសួងមហាផ្ទៃ លើកគម្រោងផែនការហ្វឹកហ្វឺនបណ្តុះបណ្តាលអំពីមុខជំនាញដល់មន្ត្រីនគរបាលទេសចរណ៍។ ក្រសួងមហាផ្ទៃ អាចសហការជាមួយក្រសួងទេសចរណ៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការងារបណ្តុះបណ្តាលនេះ។

៥-ក្រសួងមហាផ្ទៃ មានភារកិច្ចចូលរួមជាមួយក្រសួងទេសចរណ៍ ក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីកាតព្វកិច្ច និងផលប្រយោជន៍ នៃវិស័យទេសចរណ៍។

៦-ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវគាំទ្រ និងជម្រុញការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពនគរបាលទេសចរណ៍ឱ្យមានការអភិវឌ្ឍន៍ រីកចម្រើនស្របតាមគោលនយោបាយជាតិ លើវិស័យទេសចរណ៍។

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

បណ្ណាគារភក្តីឡង
PheakdeyLaw Book Store

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ០៣ ឆ្នាំ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រាបី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com